ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

## ឯកឧត្តម ទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលជួបជាមួយ ឯកឧត្តម Doug Ericksen សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក នៃរដ្ឋវ៉ាស៊ីនតោន ឯកឧត្តម Doug Ericksen៖ ចង់ឃើញកម្ពុជា និងអាមេរិកមានទំនាក់ទំនងល្អ

******

**ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឱ្យ**ឯកឧត្តម** Doug Ericksen សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិកនៃរដ្ឋវ៉ាស៊ីនតោន ចូលជួបសម្តែងការគួរសមនៅថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៨។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូវការស្វាគមន៍យ៉ាងរាក់ទាក់កក់ក្តៅចំពោះឯកឧត្តម Doug Ericksen និងប្រតិភូដែលបានអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជាជាលើកទី២ និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម ដែលបានផ្តល់នូវការវាយតម្លៃប្រកបដោយយុត្តិធម៌ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការនាំមកនូវសន្តិភាព ស្ថិរភាព ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចក៏ដូចជាការគោរពដល់សិទ្ធិអធិបតេយ្យ ស្វ័យសំរេចរបស់កម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានមានប្រសាសន៍បន្តទៀតថា បច្ចុប្បន្នកម្ពុជាមានសន្តិភាពពេញលេញអាស្រ័យដោយនយោបាយឈ្នះឈ្នះ ដែលផ្តួចផ្តើមដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ ប្រជាជនកម្ពុជាមានសំណាងណាស់ដែលបានរស់នៅយ៉ាងសុខសាន្តក្រោមដំបូលសន្តិភាពនាពេលបច្ចុប្បន្ននេះ ក្នុងពេលដែលប្រទេសមួយចំនួននៅតំបន់មជ្ឈិមបូព៌ាបានជួបប្រទះភ្លើងសង្គ្រាម និងសោកនាដ្ឋកម្មឥតឈប់ឈរដោយសារតែសង្គ្រាមរ៉ាំរ៉ៃផ្ទៃក្នុង។ សន្តិភាពនេះក៏បានផ្តល់ឱ្យកម្ពុជានូវឱកាសក្នុងការអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចំរើនលូតលាស់ប្រកបដោយចិរភាពរហូតមកដល់សព្វថ្ងៃ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានកត់សំគាល់ថា កម្ពុជានិងសហរដ្ឋអាមេរិកមាននូវទំនាក់ទំនងមិត្តភាពនិងកិច្ចសហប្រតិបត្តិការល្អនាពេលកន្លងមក។ ទោះបីមានចំណុចខ្លះមិនស្របគ្នាក្នុងទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិកក្តី ប៉ុន្តែក៏មានកិច្ចសហប្រតិបត្តិការជាច្រើនទៀតដែលប្រទេសទាំងពីរអាចរួមគ្នាដោះស្រាយដូចជា ការប្រឆាំងអំពើភេរវកម្ម ការជួញដូរមនុស្ស ឧក្រិដ្ឋកម្មឆ្លងដែន និងការជួញដូរគ្រឿងញៀន។ល។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះសហរដ្ឋអាមេរិក ដែលបានផ្តល់ជំនួយអភិវឌ្ឍន៍ដល់កម្ពុជាក្នុងរយៈកាលកន្លងមក ជាពិសេសពេលថ្មីៗនេះអាមេរិកបានបន្តផ្តល់ជំនួយចំនួន៤លានដុល្លារដល់ការជួយដល់ការដោះមីន គ្រាប់បែកចង្កោម និងគ្រាប់បែកមិនទាន់ផ្ទុះនៅកម្ពុជារយៈពេលពីរឆ្នាំ (២០១៨-២០១៩)និងផ្តល់ប្រព័ន្ធអនុគ្រោះពន្ធ (GSP) រយៈពេល ៣ឆ្នាំទៀតដល់កម្ពុជា ។

**ឯកឧត្តម Doug Ericksen** បានសម្តែងនូវសេចក្តីរីករាយ ដោយបានអញ្ជើញមកបំពេញទស្សនកិច្ចជាលើកទី២នេះ ហើយបានឃើញពីការអភិវឌ្ឍជាច្រើននៅក្នុងប្រទេសកម្ពុជា បើប្រៀបធៀបទៅនឹងទស្សនកិច្ចរបស់លោកកាលពីឆ្នាំ២០១៦ កន្លងមកនេះ។

**ឯកឧត្តម Doug Ericksen** បានចាត់ទុកគោលនយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើប្រទេសឲ្យមានសន្តិភាព និងស្ថិរភាពជាគំរូដ៏ល្អប្រសើរសំរាប់ប្រទេសផ្សេងៗទៀតដើម្បីរៀនសូត្រដកពិសោធន៍ ពិសេសបណ្តាប្រទេសមួយចំនួនដែលមានសង្គ្រាមបែកបាក់ផ្ទៃក្នុងរហូតមកដល់សព្វថ្ងៃនេះ។ ឯកឧត្តមក៏បានសម្តែងការកោតសរសើរចំពោះការដឹកនាំរបស់រាជរដ្ឋាភិបាល ក្នុងការថែរក្សាបានសន្តិភាពពេញលេញនៅទូទាំងប្រទេសនាពេលបច្ចុប្បន្ន។

**ឯកឧត្តម Doug Ericksen** បានគូសបញ្ជាក់ថា តាមរយៈគោលនយោបាយថ្មីរបស់**ឯកឧត្តមប្រធានាធិបតី Donald Trump** ក្នុងការគោរពសិទ្ធិស្វ័យសំរេចរបស់រដ្ឋអធិបតេយ្យភាពនោះ លោកមានសុទិដ្ឋិនិយមយ៉ាងមុតមាំថាកម្ពុជា និងសហរដ្ឋអាមេរិកនឹងមានទំនាក់ទំនងល្អ។

ឯកឧត្តម **Doug Ericksen** ក៏បានថ្លែងកោតសរសើរចំពោះការបោះឆ្នោតដែលកម្ពុជាបានរៀបចំនៅឆ្នាំ២០១៧កន្លងមក និងគូសបញ្ជាក់ថាលោកមានបំណងអញ្ជើញមកធ្វើជាអ្នកសង្កេតការណ៍នៅក្នុងការបោះឆ្នោតនៅកម្ពុជានាខែកក្កដាខាងមុខនេះ។ ឯកឧត្តមក៏បានសន្យាថា នឹងជួយលើកទឹកចិត្តដល់អ្នកវិនិយោគទុនអាមេរិកឱ្យចូលរួមអភិវឌ្ឍន៍ប្រទេសកម្ពុជាឱ្យបានកាន់ច្រើនថែមទៀតនាពេលខាងមុខនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូវការស្វាគមន៍ចំពោះ**ឯកឧត្តម** Doug Ericksen ដែលមានបំណងអញ្ជើញមកធ្វើជាអ្នកសង្កេតការណ៍នៅក្នុងការបោះឆ្នោតនៅកម្ពុជានៅក្នុងខែកក្កដា ខាងមុខនេះ និងបានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមដែលមានឆន្ទៈក្នុងការជំរុញឱ្យមានកិច្ចសហប្រតិបត្តិការល្អប្រសើររវាងប្រទេសទាំងពីរ កម្ពុជា-សហរដ្ឋអាមេរិក។

ថ្ងៃសុក្រ ១២រោច ខែ ពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ភ្នំពេញ, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៨